ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបប្រតិភូសាជីវកម្មវិស្វកម្មសំណង់អន្តរជាតិ នៃប្រទេសចិន **(EICEC)**



នៅរសៀលថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ២០១៥ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម បានទទួលជួបប្រតិភូ សាជីវកម្មវិស្វកម្មសំណង់អន្តរជាតិ នៃប្រទេសចិន (EICEC) ដឹកនាំដោយលោក **Zhang HuaiPu** ជាប្រធានសាជីវកម្មវិស្វកម្មសំណង់អន្តរជាតិ នៃប្រទេសចិន (EICEC) ដើម្បីពិភាក្សាការងារ នៅទីស្តីការក្រសួង ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងលើកឡើងពីទំនាក់ទំនងដ៏ល្អយូរអង្វែង រវាងកម្ពុជា–ចិន ដែលបច្ចុប្បន្នឈានដល់ដៃគូកិច្ចសហប្រតិបត្តិការយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ។ ហើយក៏បានថ្លែងអំណរគុណចំពោះប្រទេសចិន ដែលបានផ្តល់ជំនួយអភិវឌ្ឍន៍ជាច្រើនដល់កម្ពុជា ពិសេសជំនួយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ស្ពាន ថ្នល់ ជាដើម ។ ឯកឧត្តមទេសរដ្ឋមន្ត្រី សង្ឃឹមថា ក្នុងដំណើរទស្សនកិច្ចនេះ សាជីវកម្មវិស្វកម្មសំណង់អន្តរជាតិ នៃប្រទេសចិន (EICEC) នឹងពិនិត្យលទ្ធភាព និងសម្រេចនូវគម្រោងវិនិយោគរបស់ខ្លួននៅកម្ពុជា ។



លោក **Zhang HuaiPu** ប្រធានសាជីវកម្មវិស្វកម្មសំណង់អន្តរជាតិ នៃប្រទេសចិន ដែលជាសាជីវកម្មរបស់រដ្ឋ (EICEC) បានបញ្ជាក់ថា៖ យោងតាមទំនាក់ទំនងដ៏ល្អ និងការជម្រុញលើកទឹកចិត្តពីរដ្ឋាភិបាលចិន ឱ្យក្រុមហ៊ុនចិនធ្វើការបណ្តាក់ទុន វិនិយោគឱ្យបានច្រើន នៅក្រៅប្រទេស សាជីវកម្មរបស់លោកមានការចាប់អារម្មណ៍ខ្លាំង ចំពោះការបណ្តាក់ទុននៅកម្ពុជា ។ ជាក់ស្តែង ក្នុងដំណើរបេសកកម្ម ក្នុងថ្ងៃទី៣ នេះ ប្រតិភូរបស់លោក បានធ្វើទស្សនៈកិច្ច នៅតំបន់មួយចំនួន ដូចជា៖ ព្រលានយន្តហោះអន្តរជាតិភ្នំពេញ-អតីតព្រលានយន្តហោះកំពង់ឆ្នាំង តំបន់សេដ្ឋកិច្ច និងតំបន់ឧស្សាហកម្មមួយចំនួន ។ ជាលទ្ធផល ក្រុមហ៊ុនរបស់លោកមានបំណងចង់វិនិយោគស្ថាបនាឡើងវិញនូវអតីតព្រលានយន្តហោះខេត្តកំពង់ឆ្នាំង និងសូមការណែនាំពីឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ។

ជាការឆ្លើយតប ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានស្វាគមន៍ អបអរសាទរ ចំពោះគម្រោងវិនិយោគខាងលើ ព្រោះនេះជាគំនិតរបស់ឯកឧត្តម តាំងពី ជាង២០ ឆ្នាំមុន ដែលឯកឧត្តម ធ្វើជាទេសរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ពីព្រោះអតីតព្រលានយន្តហោះកំពង់ឆ្នាំងមានទីតាំងស្ថិតនៅចំកណ្តាលអាស៊ាន ។ ដូច្នេះគឺមានអត្ថប្រយោជន៍ណាស់សម្រាប់ការកសាងព្រលានយន្តហោះបម្រើឱ្យការដឹកជញ្ជូនទំនិញ និងអ្នកដំណើរផងដែរ ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបញ្ជាក់ថា៖ បើព្រលានយន្តហោះនេះដំណើរការគឺអាចដឹកជញ្ជូនទំនិញត្រឹម ២ម៉ោងកន្លះ ទៅ៣ ម៉ោង ដើម្បីទៅកាន់ប្រទេសអាស៊ាននានាជុំវិញកម្ពុជា ។ ឯកឧត្តម ក៏បានលើកឡើងពីគម្រោងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍន៍បណ្តាញតភ្ជាប់ក្នុងប្រទេស ដូចជា៖ការធ្វើផ្លូវ Highway ពីភ្នំពេញ-កំពង់ឆ្នាំង ការធ្វើស្ពានឆ្លងកាត់ទន្លេសាប ពីកំពង់ឆ្នាំង ទៅកាន់ខេត្តកំពង់ធំ ។ ក្រៅពីនេះក៏មានគម្រោងអភិវឌ្ឍន៍ក្នុងតំបន់ផងដែរ ដូចជា៖ គម្រោងអភិវឌ្ឍន៍ត្បូងៗ រវាងអាស៊ាន-ជប៉ុន ក្នុងក្របខ័ណ្ឌមហាអនុតំបន់ទន្លេមេគង្គ GMS គម្រោងផ្លូវ highway អាស៊ាន ជាដើម ដែលខេត្តកំពង់ឆ្នាំង បានក្លាយជាចំណុចប្រសព្វ នៃគម្រោងអភិវឌ្ឍន៍ខាងលើនេះ ។

លោក **Zhang HuaiPu** ប្រធានប្រតិភូ បានចាប់អារម្មណ៍ខ្លាំង និងកាន់តែមានឆន្ទៈឡើង ក្រោយពីបានស្តាប់ការពន្យល់ណែនាំពីឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ។ ពេលត្រឡប់ទៅវិញ លោក និងពិភាក្សាជាមួយក្រុមប្រឹក្សាក្រុមហ៊ុន សាជីវកម្ម ដើម្បីពិនិត្យសម្រេចលើគម្រោងកសាងឡើងវិញនូវអតីតព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ។